ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
សំណុំរឿងរដ្ឋប្បវេណីលេខ ៦៤៣
ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២
**សាលក្រមរដ្ឋប្បវេណីលេខ ៨៣ "ផ"**
ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើមចោទឈ្មោះ [redacted] **វ៉ាន់ផន** ភេទប្រុស កើតឆ្នាំ១៩៩៤ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន [redacted]

អ្នកតំណាងដោយអាណត្តិ៖ លោកស្រីមេធាវី [redacted]

ចុងចម្លើយឈ្មោះ [redacted] **ម៉ានី** ភេទស្រី កើតឆ្នាំ១៩៩៤ សញ្ជាតិខ្មែរ មុខរបរកម្មការិនី [redacted]

អ្នកតំណាងដោយអាណត្តិ៖ លោកមេធាវី [redacted]។

## អង្គហេតុ និងចំណុចវិវាទ

**១-ខ្លឹមសារនៃសាលក្រមដែលដើមចោទប្តឹងទាមទារ**

ក-ទាមទារលែងលះពីចុងចម្លើយ

ខ-សុំអំណាចមេបាលើកូនឈ្មោះ [redacted] សុវណ្ណអ៊ីផេន ភេទប្រុស ។

**២-ការពន្យល់សង្ខេបអំពីរឿងក្តី**

កាលពីឆ្នាំ២០១៨ ដើមចោទឈ្មោះ [redacted] **វ៉ាន់ផន** និងចុងចម្លើយឈ្មោះ [redacted] **ម៉ានី** បានរៀបអាពាហ៍ពិពាហ៍នឹងគ្នាដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ហើយនៅក្នុងអំឡុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធមានកូនម្នាក់ឈ្មោះ [redacted] **សុវណ្ណអ៊ីផេន** ភេទប្រុស កើតថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ប៉ុន្តែពុំមានទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ។ នៅក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍នោះ គូភាគីតែងតែមានទំនាស់ក្នុងគ្រួសារជាញឹកញាប់ និងរស់មិនចុះសម្រុងនឹងគ្នា ហើយបានរស់នៅបែកលំនៅជាមួយគ្នាតាំងពីឆ្នាំ២០២២ រហូតដល់សព្វថ្ងៃ ដែលជាហេតុ



Scanned with CamScanner

បណ្តាលឱ្យគូភាគីអស់មនោសញ្ចេតនាក្នុងការរួមរស់នឹងគ្នាជាប្តីប្រពន្ធ និងមិនអាចបន្តរួមរស់ជាមួយគ្នាតទៅទៀតបាន ទើបដើមចោទដាក់ពាក្យបណ្តឹងមកតុលាការប្តឹងទាមទារលែងលះគ្នាតាមច្បាប់។

**៣-សេចក្តីថ្លែងការណ៍របស់គូភាគី**

-ដើមចោទឈ្មោះ [redacted] **វ៉ាន់ផន** បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំបាទប្តឹងទាមទារសុំឱ្យតុលាការចេញសាលក្រមដែលខ្លឹមសារដូចក្នុងចំណុចទី១ខាងលើនេះ ដោយហេតុថាកាលពីឆ្នាំ២០១៨ ខ្ញុំបាទ និងចុងចម្លើយបានរៀបការជាមួយគ្នាដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ យើងខ្ញុំបានទាក់ទង និងស្រលាញ់គ្នាដោយខ្លួនឯងមិនមែនឪពុកម្តាយផ្សំផ្គុំនោះទេ ហើយមុនពេលរៀបការបានស្គាល់គ្នារយៈពេល ៣ ទៅ ៤ ឆ្នាំ នៅពេលរៀបការរួចក៏ទៅរស់នៅផ្ទះខាងគ្រួសារខ្ញុំ ខ្ញុំមិនយល់ព្រមត្រូវគ្នាវិញនោះទេ។ នៅអំឡុងពេលរស់នៅបែកគ្នានោះ ខ្ញុំក៏ធ្លាប់ជួយផ្គត់ផ្គង់ចិញ្ចឹមកូនដោយមិនដែលប្រើហិង្សា និងសំឡុតគម្រាមទៅលើកូននោះទេ ហើយខ្ញុំមានស្ថានភាពសេដ្ឋកិច្ចប្រសើរជាងចុងចម្លើយទៀតផង។ នៅក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍នោះចុងចម្លើយបានចុះចេញពីផ្ទះ ហើយរស់នៅមិនចុះសម្រុងគ្នាតែងតែមានរឿងដដែល១ និងមានជម្លោះជាមួយគ្រួសារខ្ញុំជាញឹកញាប់ ដែលជាហេតុបណ្តាលឱ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធ និងមិនអាចបន្តរួមរស់ជាមួយគ្នាតទៅទៀតបាន ទើបខ្ញុំបាទដាក់ពាក្យបណ្តឹងទាមទារលែងលះគ្នា និងស្នើសុំតុលាការសម្រេចតាមការទាមទារ។

-ចុងចម្លើយឈ្មោះ [redacted] **ម៉ានី** បានធ្វើសេចក្តីថ្លែងការណ៍តបវិញថា៖ នាងខ្ញុំទទួលស្គាល់ចំពោះអង្គហេតុ និងមូលហេតុនៃការទាមទារ ហើយក៏ឯកភាពចំពោះការលែងលះគ្នា។ នៅអំឡុងពេលទៅរស់នៅផ្ទះខាងដើមចោទនោះ ខ្ញុំធ្លាប់ចុះចេញពីផ្ទះពីរលើកមែន ព្រោះពេលមានជម្លោះនឹងគ្នានោះឪពុកក្មេក និងដើមចោទបានដេញនាងខ្ញុំចេញពីផ្ទះ ហើយជម្លោះលើកទីមួយដោយសារតែដើមចោទក្បត់ចិត្តខ្ញុំធ្លាប់តាមទាន់ទៀតផង រីឯលើកទី២ព្រោះមានជម្លោះជាមួយប្អូនថ្លៃស្រីឪពុកក្មេកឃាត់មិនស្តាប់ ពេលនោះទាំងដើមចោទ និងសាច់ញាតិរបស់ដើមចោទ បានបណ្តេញខ្ញុំចេញពីផ្ទះទៀត ខ្ញុំក៏ចាកចេញរហូតដល់សព្វថ្ងៃតែម្តង។ ក្រោយមកសាច់ញាតិខាងដើមចោទ និងខ្ញុំបានត្រូវរ៉ូវគ្នាវិញ តែដើមចោទមិនព្រមរាប់រកខ្ញុំនោះទេ។ ចំពោះកូនគឺបានរស់នៅជាមួយគ្រួសារខ្ញុំនៅស្រុកកៀនស្វាយរហូតដល់សព្វថ្ងៃ នាងខ្ញុំទៅធ្វើការចេញចូលទៅផ្ទះព្រឹកល្ងាច ហើយខ្ញុំទទួលបន្ទុកចិញ្ចឹមបីបាច់ និងបង់ថ្លៃសិក្សារបស់កូនតែម្នាក់ឯង កន្លងមកដើមចោទធ្លាប់ទំនុកបម្រុងដល់កូនតិចតួចដែរតែទម្រាំទទួលបានវេទនា និងមិនទាន់ពេលវេលាទេ។ ហេតុនេះនាងខ្ញុំស្នើសុំអំណាចមេបាលើកូន និងអាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន ៦០០.០០០ រៀល ក្នុងមួយខែ។

**៤-អំពីភស្តុតាង**

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ១៨ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨។ (ថតចម្លង)

-សំបុត្រកំណើតលេខ ២៧២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុវណ្ណស៊ីផេន។ (ថតចម្លង)

**៥-ចំណុចវិវាទ៖** តើឪពុក ឬម្តាយ ដែលជាអ្នកមានលក្ខណៈសម្បត្តិគួរទទួលបាននូវអំណាចមេបាលើកូន?

## សំអាងហេតុ

១-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទមានលក្ខណៈសមស្របតាមមាត្រា ៨ និងមាត្រា១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ហេតុនេះតុលាការអាចយករឿងក្តីនេះមកពិនិត្យ និងចាត់ការតាមច្បាប់បាន។

២-តាមសេចក្តីថ្លែងការណ៍របស់គូភាគីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុ



Scanned with CamScanner

ផលដោយផ្ទាល់មាត់ ឃើញថា៖ ដើមចោទបានប្ដឹងទាមទារលែងលះពីចុងចម្លើយ និងសុំអំណាចមេបាលើកូន ដោយពុំមានទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ ហើយចុងចម្លើយបានឯកភាពចំពោះការលែងលះ តែខ្លួនសុំអំណាចមេបាគ្រប់គ្រងកូន និងអាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន ៦០០.០០០ រៀល ក្នុងមួយខែ។ ហេតុនេះគប្បីតុលាការពិចារណាដោយផ្អែកទៅលើផលប្រយោជន៍របស់កូន។

៣-តាមសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ១៨ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ ចេញដោយមេឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ឃើញថា៖ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ ដើមចោទ និងចុងចម្លើយពិតជាបានរៀបការជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ប្រាកដមែន ហើយគូភាគីបានរស់នៅបែកលំនៅឋានពីគ្នាតាំងពីឆ្នាំ២០២២ ដែលបណ្ដាលឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាននោះទេ។

៤-តាមសំបុត្រកំណើតលេខ ២៧២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងទំពន់ទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ បានបញ្ជាក់ថា៖ នៅក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍នោះ ដើមចោទ និងចុងចម្លើយពិតជាមានកូនម្នាក់ឈ្មោះ [redacted] **សុវណ្ណអ៊ីផេន** ភេទប្រុស កើតថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ប្រាកដមែន ហើយគូភាគីមិនបានឯកភាពគ្នាអំពីអំណាចមេបានោះទេ។ ហេតុនេះគប្បីតុលាការសម្រេចកំណត់អំពីអ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ តាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

៥-ផ្អែកតាមមាត្រា ១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានចែងថា៖ ឪពុក ឬម្ដាយ ដែលពុំមានអំណាចមេបាក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។

៦-ចំពោះរឿងក្ដីនេះ តុលាការអស់លទ្ធភាពក្នុងការផ្សះផ្សាឱ្យគូភាគីសះជានឹងគ្នាហើយ។

៧-ប្រាក់ប្រដាប់ក្ដីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្ដីសម្រេចបញ្ចប់

១-ទទួលស្គាល់ពាក្យបណ្ដឹង ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] **វ៉ាន់ជន** ទុកជាត្រឹមត្រូវតាមច្បាប់។ ឱ្យដើមចោទឈ្មោះ [redacted] **វ៉ាន់ជន** និងចុងចម្លើយឈ្មោះ [redacted] **ម៉ានី** លែងលះគ្នា ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

២-ប្រគល់អំណាចមេបាឱ្យទៅឈ្មោះ [redacted] **ម៉ានី** គ្រប់គ្រងលើកូនឈ្មោះ [redacted] **សុវណ្ណអ៊ីផេន** ភេទប្រុស កើតថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

៣-ឱ្យដើមចោទឈ្មោះ [redacted] **វ៉ាន់ជន** ផ្ដល់អាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន ៦០០.០០០ (ហុកសិបម៉ឺន) រៀល ក្នុងមួយខែ ។

៤-ឈ្មោះ [redacted] **វ៉ាន់ជន** មានសិទ្ធិអាចចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន តាមពេលវេលាសមរម្យ តាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៥-ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់ដើមចោទ។



Scanned with CamScanner

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ចំពោះមុខគូភាគី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា៖ [redacted]

---

*"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"*

ថ្ងៃពុធ ១០រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner